01000349

D202

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: 00៤/0៧-0៩-២00៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: មេធាវីការពារក្តី[redacted]

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១៤

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 04-Jul-2014, 09:36
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ ~~សម្ងាត់/Confidential~~ សាធារណៈ / Public

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់[redacted]ទៅសហចៅក្រមស៊ើបអង្កេតសុំបង្គាប់ទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស ឲ្យបញ្ឈប់នូវការដាក់ឯកសារនានារបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿងភ្លាម**

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវី**

សូ ម្ងាស្សូវ៉ី

Suzana TOMANOVIĆ

**<u>ផ្ញើជូន៖</u>**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Mark B. HARMON

**សហព្រះរាជអាជ្ញា៖**

**ជា លាង**

Nicholas KOUMJIAN

**ក្រុមមេធាវីការពារក្តីទាំងអស់ក្នុងសំណុំរឿង 00៤**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង 00៤**

តាមរយៈសហមេធាវី ("មេធាវីការពារក្តី") របស់គាត់ និងដោយអនុលោមតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ, មាត្រា ១២(២) នៃកិច្ចព្រមព្រៀង,[1] មាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក,[2] មាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") និង វិធាន ២១(១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") [redacted] សូមស្នើសុំសហចៅក្រមស៊ើបអង្កេត បង្គាប់ទៅក្រឡាបញ្ជីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ឱ្យបញ្ចូលនានារបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿងភ្លាម។ ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនបានបញ្ចូល ឬបញ្ចូលដោយយឺតយ៉ាវនូវការដាក់ឯកសារនានារបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿង។ ហេតុនេះ មេធាវីការពារក្តីត្រូវបានបដិសេធមិនផ្តល់ឱកាសឱ្យបញ្ចូលឯកសាររបស់ខ្លួនជាកំណត់ហេតុឱ្យបានភ្លាមៗ ឬត្រូវបានបដិសេធមិនផ្តល់ឱកាសឱ្យបញ្ចូលឯកសាររបស់ខ្លួនជាកំណត់ហេតុទាល់តែសោះតែម្តង ដែលទង្វើនេះគឺជាការរំលោភបំពានដល់សិទ្ធិជាសារវ័ន្តរបស់[redacted]។ សំណើសុំនេះត្រូវធ្វើឡើងជាចាំបាច់ដើម្បី៖ ក.ការពារសិទ្ធិរបស់[redacted]ក្នុងការការពារក្តីរបស់ខ្លួន ខ.ការពារសិទ្ធិរបស់[redacted] ក្នុងការប្តឹងឧទ្ធរណ៍ គ.ធានាសច្ចភាពគតិយុត្តិនៅ អ.វ.ត.ក អនុលោមតាមវិធាន ២១ និង ឃ.ធានាឱ្យទម្លាប់អនុវត្តនៅ អ.វ.ត.ក ក្លាយជាទម្លាប់អនុវត្តគំរូដល់តុលាការផ្សេងៗទៀត[3]។មេធាវីការពារក្តីស្នើសុំដាក់សំណើនេះជាភាសាអង់គ្លេស ដោយមានការបកប្រែជាភាសាខ្មែរតាមក្រោយ ពីព្រោះអង្គភាពបកប្រែមិនអាចបញ្ចប់ការបកប្រែទាន់ពេលបាន ដោយសារតែមានការងារជាអាទិភាពផ្សេងទៀត[4]។

## I. សាវតារ

---

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង")។

[2] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

[3] អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា បើទោះបីជា អ.វ.ត.ក មិនមានអាណត្តិការងារដោះស្រាយនូវភាពខ្វះចន្លោះដោយផ្ទាល់នៅក្នុងយន្តការនៃតុលាការជាតិដែលបានបង្កើតឡើងដើម្បីធានាទ្រទ្រង់នូវឯករាជភាពរបស់ស្ថាប័នតុលាការក៏ដោយ "តែ វាអាចជា*តុលាការគំរូ* សម្រាប់ជួយជំរុញឱ្យមានការធានានូវឯករាជភាព និងសុចរិតភាពនៅក្នុងស្ថាប័នតុលាការ")។ *សំណុំរឿង ០០២,* សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន និង សំណើពាក់ព័ន្ធផ្សេងៗ, ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១, ឯកសារ E5/3 ("សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន"), កថាខណ្ឌ ១៤ (គូសបញ្ជាក់បន្ថែម)។

[4] សូមមើលអ៊ីមែលពីអង្គភាពបកប្រែផ្ញើមកមេធាវីការពារក្តី "ការបកប្រែសំណើ" ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៤

១. នៅថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់ "សំណើជាបន្ទាន់របស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ"[5] ជាភាសាអង់គ្លេសទៅ ក.ស.ច.ស។ នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់សំណៅជាភាសាខ្មែរនៃសំណើនេះ[6]។ នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានផ្ញើសារអេឡិកត្រូនិចទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស សាកសួរថា តើសំណើនេះត្រូវបានបញ្ចូលក្នុងសំណុំរឿងហើយឬនៅ បើមិនទាន់បានបញ្ចូលទេ តើដោយសារមូលហេតុអ្វី[7]។ នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៤ ក្រឡាបញ្ជីរបស់ ក.ស.ច.ស បានឆ្លើយតបក្នុងសារអេឡិកត្រូនិចថា "ខ្ញុំបានទទួលសំណើរបស់លោកហើយ។ ក្រុមមេធាវីរបស់លោកនឹងបានទទួលព័ត៌មានអំពីស្ថានភាពនៃឯកសារនេះក្នុងពេលវេលាសមស្រប"[8]។ នៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានផ្ញើសារអេឡិកត្រូនិចម្តងទៀតទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស ដោយសាកសួរថា តើសំណើនេះត្រូវបានបញ្ចូលក្នុងសំណុំរឿងហើយឬនៅ បើមិនទាន់បានបញ្ចូលទេ តើដោយសារមូលហេតុអ្វី[9]។ ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនបានឆ្លើយតបទៅនឹងសារអេឡិកត្រូនិចថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៤ នេះទេ។ សំណើនេះត្រូវបានជូនដំណឹងទៅភាគីនៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤[10]។

២. នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់ "សំណើជាបន្ទាន់របស់ [redacted]

---

[5] សំណើជាបន្ទាន់របស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ, ចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ D186 ("សំណើសុំចូលពិនិត្យមើលសំណុំរឿង")។ ភស្តុតាងនៃការដាក់ សំណើសុំចូលពិនិត្យមើលសំណុំរឿង, ភាសាអង់គ្លេស, ចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១៤។

[6] ភស្តុតាងនៃការដាក់ សំណើសុំចូលពិនិត្យមើលសំណុំរឿង, ភាសាខ្មែរ, ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤។

[7] សារអេឡិកត្រូនិចពីមេធាវីការពារផ្ញើជូនក្រឡាបញ្ជីរបស់ ក.ស.ច.ស ដែលមានចំណងជើងថា "ការដាក់ឯកសារនានាទៅក្នុងសំណុំរឿង", ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៤។

[8] សារអេឡិកត្រូនិចពីក្រឡាបញ្ជីរបស់ ក.ស.ច.ស ផ្ញើជូនមេធាវីការពារក្តី ដែលមានចំណងជើងថា "យោង៖ សារណានានាទៅក្នុងសំណុំរឿង", ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៤។

[9] សារអេឡិកត្រូនិចពីមេធាវីការពារផ្ញើជូនក្រឡាបញ្ជីរបស់ ក.ស.ច.ស ដែលមានចំណងជើងថា "យោង៖ សារណានានាទៅក្នុងសំណុំរឿង", ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៤។

[10] សារអេឡិកត្រូនិចពីមន្ត្រីដែលជូនដំណឹងពីសំណុំរឿងផ្ញើជូនមេធាវីការពារក្តី ដែលមានចំណងជើងថា "ផ្ញើជូនបន្ត៖ [ដាក់ដោយមេធាវីការពារក្តី (សំណុំរឿង ០០៤)] **ឯកសារថ្មីៗ៖ សំណុំរឿងលេខ ០០៤** - (សំណើជាបន្ទាន់របស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ)", ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤។

សុំដំណោះស្រាយដោយផ្អែកលើព័ត៌មានថ្មី"[11] ជាភាសាអង់គ្លេស និងសំណៅបកប្រែជាភាសាខ្មែរ ជូនទៅ ក.ស.ច.ស។ សំណើនេះត្រូវបានជូនដំណឹងទៅភាគីនៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៤[12]។

៣. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់ "សេចក្តីជូនដំណឹងរបស់[redacted] អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើជាបន្ទាន់របស់ [redacted] សុំដំណោះស្រាយដោយផ្អែកលើព័ត៌មានថ្មី"[13] ជាភាសាអង់គ្លេស និងសំណៅបកប្រែជាភាសាខ្មែរ ជូនទៅ ក.ស.ច.ស។ សំណើនេះត្រូវបានជូនដំណឹងទៅភាគីនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤[14]។

៤. នៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់ "សារណារបស់[redacted]ស្តីពីការពិចារណាសារជាថ្មីទៅលើសេចក្តីសម្រេចក្នុងការអនុញ្ញាតឱ្យ[redacted] ចូលពិនិត្យមើលសំណុំរឿង"[15] ជាភាសាអង់គ្លេសជូនទៅ ក.ស.ច.ស។ នៅថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានផ្ញើសារអេឡិកត្រូនិចទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស ដោយសាកសួរថាតើ

---

[11] សំណើជាបន្ទាន់របស់[redacted]សុំដំណោះស្រាយដោយផ្អែកលើព័ត៌មានថ្មី, ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ D192 ("សំណើបន្ទាន់សុំដំណោះស្រាយ")។ ភ័ស្តុតាងនៃការដាក់, សំណើបន្ទាន់សុំដំណោះស្រាយ, ភាសាអង់គ្លេស និងភាសាខ្មែរ, ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤។

[12] សារអេឡិកត្រូនិចពីមន្ត្រីដែលជូនដំណឹងពីសំណុំរឿងផ្ញើជូនមេធាវីការពារក្តី ដែលមានចំណងជើងថា "ផ្ញើជូនបន្ត៖ [ដាក់ដោយមេធាវីការពារក្តី (សំណុំរឿង ០០៤)] **ឯកសារថ្មីៗ៖ សំណុំរឿងលេខ ០០៤** - (សំណើជាបន្ទាន់របស់[redacted]សុំដំណោះស្រាយដោយផ្អែកលើព័ត៌មានថ្មី)", ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៤។

[13] សេចក្តីជូនដំណឹងរបស់[redacted] អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើជាបន្ទាន់របស់ [redacted] សុំដំណោះស្រាយដោយផ្អែកលើព័ត៌មានថ្មី ("សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍"), ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ D192/1/1។ ភស្តុតាងនៃការដាក់ សំណើបន្ទាន់សុំដំណោះស្រាយ, ភាសាអង់គ្លេស និងភាសាខ្មែរ, ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤។

[14] សារអេឡិកត្រូនិចពីមន្ត្រីដែលជូនដំណឹងពីសំណុំរឿងផ្ញើជូនមេធាវីការពារក្តី ដែលមានចំណងជើងថា "ផ្ញើជូនបន្ត៖ [ដាក់ដោយ ក.ស.ច.ស] **ឯកសារថ្មីៗ៖ សំណុំរឿងលេខ ០០៤** - (ការចុះបញ្ជីនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ស.ច.ស.អ លើសំណើបន្ទាន់របស់[redacted])", ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤។

[15] សារណារបស់[redacted]ស្តីពីការពិចារណាសារជាថ្មីទៅលើសេចក្តីសម្រេចក្នុងការអនុញ្ញាតឱ្យ[redacted] ចូលពិនិត្យមើលសំណុំរឿង, ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ D186/2 ("សារណាស្តីពីការពិចារណាសារជាថ្មីពីការចូលពិនិត្យមើលសំណុំរឿង")។ ភ័ស្តុតាងនៃការដាក់ សារណាស្តីពីការពិចារណាសារជាថ្មីពីការចូលពិនិត្យមើលសំណុំរឿង, ភាសាអង់គ្លេស, ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤។

01000353



សារណានេះត្រូវបានបញ្ចូលក្នុងសំណុំរឿងហើយឬនៅ បើមិនទាន់បានបញ្ចូលទេ តើដោយសារមូលហេតុអ្វី[16]។ នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ ក្រឡាបញ្ជីរបស់ ក.ស.ច.ស បានឆ្លើយតបទៅនឹងសារអេឡិកត្រូនិចនេះថា "សំណើនេះនឹងបញ្ចូលក្នុងសំណុំរឿងនៅថ្ងៃនេះ"[17]។ សារណានេះត្រូវបានជូនដំណឹងទៅភាគីនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤[18]។ នៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់សំណៅបកប្រែជាភាសាខ្មែរនៃសារណានេះ[19]។

៥. នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់ "ពាក្យសុំរបស់ [redacted] ស្នើសុំសហចៅក្រមស៊ើបអង្កេត ប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ"[20] ជាភាសាអង់គ្លេសជូនទៅ ក.ស.ច.ស។ នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់ពាក្យសុំនេះជាសំណៅបកប្រែភាសាខ្មែរ[21]។ នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានផ្ញើសារអេឡិកត្រូនិចទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស ដោយសាកសួរថាតើសារណានេះត្រូវបានបញ្ចូលក្នុងសំណុំរឿងហើយឬនៅ បើមិនទាន់បានបញ្ចូលទេ តើដោយសារមូលហេតុអ្វី[22]។ នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ក្រឡាបញ្ជីរបស់ ក.ស.ច.ស បានឆ្លើយទៅនឹងសារអេឡិកត្រូនិចនោះវិញថា "ខ្ញុំបានទទួលសំណើនោះហើយ។ សំណើរបស់លោកនឹងត្រូវបញ្ចូល

---

[16] សារអេឡិកត្រូនិចពីមេធាវីការពារផ្ញើជូនក្រឡាបញ្ជីរបស់ ក.ស.ច.ស ដែលមានចំណងជើងថា "សារណានានានៅក្នុងសំណុំរឿង", ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៤។

[17] សារអេឡិកត្រូនិចពីក្រឡាបញ្ជីរបស់ ក.ស.ច.ស ផ្ញើជូនមេធាវីការពារក្តី ដែលមានចំណងជើងថា "ឃោង៖ សារណានានានៅក្នុងសំណុំរឿង", ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤។

[18] សារអេឡិកត្រូនិចពីមន្ត្រីដែលជូនដំណឹងពីសំណុំរឿងផ្ញើជូនមេធាវីការពារក្តី ដែលមានចំណងជើងថា "ផ្ញើជូនបន្ត៖ [ដាក់ដោយ ក.ស.ច.ស] **ឯកសារថ្មីៗ៖ សំណុំរឿងលេខ 004** - សារណារបស់ [redacted] ស្តីពីការពិចារណាសារជាថ្មីទៅលើសេចក្តីសម្រេចក្នុងការអនុញ្ញាតឱ្យ [redacted] ចូលពិនិត្យមើលសំណុំរឿង, ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤។

[19] ភស្តុតាងនៃការដាក់សារណាស្តីពីការពិចារណាសារជាថ្មីពីការចូលពិនិត្យមើលសំណុំរឿង, ភាសាខ្មែរ, ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១៤។

[20] ពាក្យសុំរបស់ [redacted] ស្នើសុំសហចៅក្រមស៊ើបអង្កេត ប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ, ចុះថ្ងៃទី ២០ ឧសភា ឆ្នាំ ២០១៤ ("ពាក្យសុំប្រកាសមោឃភាព")។ ភស្តុតាងនៃការដាក់, ពាក្យសុំប្រកាសមោឃភាព, ភាសាអង់គ្លេស, ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤។

[21] ភស្តុតាងនៃការដាក់ ពាក្យសុំប្រកាសមោឃភាព, ភាសាខ្មែរ, ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤។

[22] សារអេឡិកត្រូនិចពីមេធាវីការពារផ្ញើជូនក្រឡាបញ្ជីរបស់ ក.ស.ច.ស ដែលមានចំណងជើងថា "សារណានានានៅក្នុងសំណុំរឿង", ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤។

ក្នុងសំណុំរឿងទៅតាមពេលវេលាសមស្រប ហើយក្រុមរបស់លោកនឹងបានទទួលដំណឹងអំពីការបញ្ចូលឯកសារនេះទៅក្នុងសំណុំរឿងមិនខាន”[23]។ នៅថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានផ្ញើសារអេឡិកត្រូនិចម្តងទៀតទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស ដោយសាកសួរថាតើសំណើនេះត្រូវបានបញ្ចូលក្នុងសំណុំរឿងហើយឬនៅ បើមិនទាន់បានបញ្ចូលទេ តើដោយសារមូលហេតុអ្វី[24]។ ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនទាន់បានឆ្លើយតបនឹងសារអេឡិកត្រូនិចថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៤ នេះទេ។ សំណើនេះមិនទាន់បានជូនដំណឹងទៅភាគីនៅឡើយទេ។

៦. នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់ “ការជូនដំណឹងរបស់ [redacted] ថា គាត់មានបំណងប្រើប្រាស់យ៉ាងពេញលេញនូវសិទ្ធិរបស់គាត់នៅស្ងៀមមិនឆ្លើយតបនឹងសំណួរនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬសមាជិកណាមួយនៃការិយាល័យសហចៅក្រមស៊ើបអង្កេត”[25] ជាភាសាអង់គ្លេស និងសំណៅបកប្រែជាភាសាខ្មែរ ជូនទៅ ក.ស.ច.ស។ ការជូនដំណឹងនេះត្រូវបានជូនដំណឹងទៅភាគីនៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤[26]។

៧. នៅថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់ “សំណើរបស់ [redacted] សុំការ

---

[23] សារអេឡិកត្រូនិចពីក្រឡាបញ្ជីរបស់ ក.ស.ច.ស ផ្ញើជូនមេធាវីការពារក្តី ដែលមានចំណងជើងថា “យោង៖ សារណានានានៅក្នុងសំណុំរឿង”, ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤។

[24] សារអេឡិកត្រូនិចពីមេធាវីការពារផ្ញើជូនក្រឡាបញ្ជីរបស់ ក.ស.ច.ស ដែលមានចំណងជើងថា “យោង៖ សារណានានានៅក្នុងសំណុំរឿង”, ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៤។

[25] ការជូនដំណឹងរបស់ [redacted] ថាគាត់មានបំណងប្រើប្រាស់យ៉ាងពេញលេញនូវសិទ្ធិរបស់គាត់នៅស្ងៀមមិនឆ្លើយតបនឹងសំណួរនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬសមាជិកណាមួយនៃការិយាល័យសហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D195 (“ការជូនដំណឹងពីសិទ្ធិរបស់ [redacted] ក្នុងការនៅស្ងៀមមិនឆ្លើយតប”)។ ភ័ស្តុតាងនៃការដាក់ការជូនដំណឹងពីសិទ្ធិរបស់ [redacted] ក្នុងការនៅស្ងៀមមិនឆ្លើយតប, ភាសាអង់គ្លេស និងភាសាខ្មែរ, ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤។

[26] សារអេឡិកត្រូនិចពីមន្ត្រីដែលជូនដំណឹងពីសំណុំរឿងផ្ញើជូនមេធាវីការពារក្តី ដែលមានចំណងជើងថា “ផ្ញើជូនបន្ត៖ [ដាក់ដោយមេធាវីការពារក្តី (សំណុំរឿង 00៤)] **ឯកសារថ្មីៗ៖ សំណុំរឿងលេខ 00៤** - ការជូនដំណឹងរបស់ [redacted] ថាគាត់មានបំណងប្រើប្រាស់យ៉ាងពេញលេញនូវសិទ្ធិរបស់គាត់នៅស្ងៀមមិនឆ្លើយតបនឹងសំណួរនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬសមាជិកណាមួយនៃការិយាល័យសហចៅក្រមស៊ើបអង្កេត” ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤។

បញ្ជាក់បំភ្លឺថា គាត់អាចបើកការស៊ើបអង្កេតដោយខ្លួនឯងបាន"[27] ជាភាសាអង់គ្លេសជូនទៅ ក.ស.ច.ស។ នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់ពាក្យសុំបំភ្លឺនេះជាសំណៅបកប្រែភាសាខ្មែរ[28]។ សំណើសុំការបញ្ជាក់បំភ្លឺនេះមិនទាន់ជូនដំណឹងមកភាគីទេ។

៨. នៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់ "សំណើរបស់ [redacted] សុំឱ្យសហចៅក្រមស៊ើបអង្កេតបង្ហាញការយល់ឃើញអំពីផ្លូវច្បាប់ ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតនៅពេលចេញដីកាដំណោះស្រាយ"[29] ជាភាសាអង់គ្លេសជូនទៅ ក.ស.ច.ស។សំណើនេះកំពុងបកប្រែដោយអង្គភាពបកប្រែ[30]។ សំណើសុំនេះមិនទាន់ជូនដំណឹងមកភាគីទេ។

៩. ដើម្បីឱ្យមានភាពងាយស្រួល ឧបសម្ព័ន្ធនៃសំណើនេះបង្ហាញពីការដាក់ឯកសារនានាដែលមេធាវីការពារក្តីបានដាក់ជូន ក.ស.ច.ស ដូចមានរៀបរាប់*ខាងក្រោម*។ ឧបសម្ព័ន្ធនេះបង្ហាញកាលបរិច្ឆេទនៃការដាក់ឯកសារនីមួយៗ ជាភាសាអង់គ្លេស និងភាសាខ្មែរ និងនៅក្នុងករណីខ្លះបង្ហាញកាលបរិច្ឆេទនៃការបញ្ចូលទៅក្នុងសំណុំរឿង។

## II. **ភាពអាចទទួលយកបាន**

១០. សំណើនេះធ្វើឡើងអនុលោមតាមវិធាន ២១។ វិធាន ២១ តម្រូវថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ញត្តិរដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង

[27] សំណើរបស់ [redacted] សុំការបញ្ជាក់បំភ្លឺថា គាត់អាចបើកការស៊ើបអង្កេតដោយខ្លួនឯងបាន, ចុះថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៤ ("សំណើសុំការបញ្ជាក់បំភ្លឺ")។ ភស្តុតាងនៃការដាក់ សំណើសុំការបញ្ជាក់បំភ្លឺ, ភាសាអង់គ្លេស, ចុះថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៤។

[28] ភស្តុតាងនៃការដាក់ សំណើសុំការបញ្ជាក់បំភ្លឺ, ភាសាខ្មែរ, ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៤។

[29] សំណើរបស់ [redacted] សុំឱ្យសហចៅក្រមស៊ើបអង្កេតបង្ហាញការយល់ឃើញអំពីផ្លូវច្បាប់ ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតនៅពេលចេញដីកាដំណោះស្រាយ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ("សំណើសុំការយល់ឃើញអំពីផ្លូវច្បាប់ ក្នុងករណីមានការខ្វែងយោបល់គ្នា")។ ភស្តុតាងនៃការដាក់ សំណើសុំការយល់ឃើញអំពីផ្លូវច្បាប់ ក្នុងករណីមានការខ្វែងយោបល់គ្នា, ភាសាអង់គ្លេស, ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤។

[30] សំណើសុំបកប្រែលើសំណើសុំការយល់ឃើញអំពីផ្លូវច្បាប់ ក្នុងករណីមានការខ្វែងយោបល់គ្នា ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤។

ជនរងគ្រោះ ដើម្បីធានានូវពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង"។ អង្គបុរេជំនុំជម្រះធ្លាប់បានពិចារណាថា គោលការណ៍ជាសារវន្តដែលមានចែងក្នុងវិធាន ២១ "តម្រូវថា អង្គបុរេជំនុំជម្រះត្រូវបកស្រាយឱ្យបានទូលំទូលាយ នូវសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថា សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលការកាត់សេចក្តីដោយយុត្តិធម៌ ត្រូវបានគាំពារ"[31]។ វិធាន ២១ អនុវត្តចំពោះជនសង្ស័យ និង ជនត្រូវចោទ ហេតុនេះ ការបកស្រាយតាមន័យទូលំទូលាយរបស់អង្គបុរេជំនុំជម្រះគួរយកមកអនុវត្ត ដោយមិនគិតដល់ឋានៈរបស់[redacted]នោះទេ។ អង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍ ដែលលើកឡើងនូវបញ្ហានៃសិទ្ធិជាសារវន្តដោយផ្អែកលើវិធាន ២១ តែមួយគត់[32]។ សហចៅក្រមស៊ើបអង្កេតគួរអនុវត្តតាមយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ និងគួរឆ្លើយតបចំពោះសំណើនេះដើម្បីធានាថា សិទ្ធិរបស់[redacted]ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគាំពារ។

## III. ច្បាប់ជាធរមាន

### ក. សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តី

១១. មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញចែងថា៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស

[31] *សំណុំរឿង ០០២,* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និង សេចក្តីសង្ខេបបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី, ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D390/1/2/4 ("សាលដីកាលើចម្លើយតបរបស់ អៀង សារី"), កថាខណ្ឌ ១៣។ *សូមមើលផងដែរ សំណុំរឿង ០០២,* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ, ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារ A190/I/20, កថាខណ្ឌ ៣៦។ *សំណុំរឿង ០០២,* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១, ឯកសារ D427/1/30, កថាខណ្ឌ ៤៩។

[32] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំឲ្យកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី, ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០, ឯកសារ D264/2/6 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ"), កថាខណ្ឌ ១៣ ដល់ ១៤។ សាលដីកាលើចម្លើយតបរបស់ អៀង សារី, កថាខណ្ឌ ១៣។

ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ”។

១២. មាត្រា ១២(២) នៃកិច្ចព្រមព្រៀងចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖ “អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាគឺជាភាគីហត្ថលេខី”។

១៣. មាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

> នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាសមស្របតាមមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖
>
> ខ. មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួន ដែលជ្រើសរើសដោយខ្លួនឯង។
>
> ឃ. ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ជនសង្ស័យ និងការពារខ្លួនដោយខ្លួនឯង ឬតាមរយៈ មេធាវី ដែលជ្រើសរើសដោយខ្លួនឯង ...។

១៤. មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

> ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម៖
>
> (ខ) ត្រូវមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។
>
> (ឃ) ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន ...។

១៥. វិធាន ២១(១) ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ញារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង។

## ខ. តួនាទីរបស់ក្រឡាបញ្ជី

១៦. វិធាន ១៤(២) ចែងថា៖ "សហចៅក្រមស៊ើបអង្កេតនីមួយៗ មានក្រឡាបញ្ជីម្នាក់។ ក្រឡាបញ្ជីត្រូវរក្សាឯកសារស៊ើបសួរ និង បំពេញសកម្មភាពដទៃទៀត តាមតម្រូវការរបស់សហចៅក្រមស៊ើបអង្កេត ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ"។

១៧. វិធាន១៦*ស្ទួន* ដែលមានចំណងជើងថា "ក្រឡាបញ្ជី" ចែងថា៖ "ដើម្បីអនុវត្តមុខងាររបស់ខ្លួននៅក្នុង អ.វ.ត.ក ដូចដែលបានចែងក្នុងវិធានផ្ទៃក្នុងនេះ មន្ត្រី អ.វ.ត.ក ដែលត្រូវបំពេញមុខងារជាក្រឡាបញ្ជី ត្រូវទទួលនីតិសម្បទាពីក្រសួងយុត្តិធម៌។ ដើម្បីបំពេញតាមតម្រូវការនេះ ការិយាល័យរដ្ឋបាលត្រូវបញ្ជូនបញ្ជីឈ្មោះក្រឡាបញ្ជី ជាបន្ទាន់ទៅក្រសួងយុត្តិធម៌ដើម្បីផ្តល់នីតិសម្បទា"។

១៨. វិធាន ៣៩(៦) ចែងថា៖

> ឯកសារទាំងអស់ ដូចជាពាក្យបណ្តឹង សំណើ និង ពាក្យសុំដែលដាក់មកអង្គជំនុំជម្រះវិសាមញ្ញ ត្រូវដាក់ជូនទៅក្រឡាបញ្ជីនៃការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ទៅតាមករណីនីមួយៗ ស្របតាមច្បាប់កម្ពុជាជាធរមាន វិធានផ្ទៃក្នុងនេះ សេចក្តីណែនាំអនុវត្ត និង សេចក្តីសម្រេចរបស់ចៅក្រម តាមករណីសមស្រប។

១៩. វិធាន ៥៥(៦) ចែងថា៖

> ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវរក្សាទុកសំណុំរឿង រួមទាំងកំណត់ហេតុ និងរបាយការណ៍នៃការស៊ើបសួរ។ សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់ មានសិទ្ធិគ្រប់ពេលវេលាក្នុងការពិនិត្យ និងថតចម្លងសំណុំរឿង ក្រោមការឃ្លាំមើល

របស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងពេលម៉ោងធ្វើការ និង គោរពទៅតាមបទបញ្ជារបស់អង្គជំនុំជម្រះវិសាមញ្ញ។

២០. វិធាន ៧៦ មានចំណងជើងថា "បណ្តឹងសុំមោឃៈភាពដោយការមិនគោរពវិធានបញ្ញត្តិ"។ វិធាន ៧៦(៣) ចែងថា៖ "ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតត្រូវចុះបញ្ជីពាក្យសុំភ្លាម។ នៅពេលដែលសហចៅក្រមស៊ើបអង្កេតសម្រេចទទួលពាក្យសុំ សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងទៅឱ្យអង្គបុរេជំនុំជម្រះ"។

២១. មាត្រា ២.១ នៃឯកសារដែលមានចំណងជើងថា "ការដាក់ឯកសារនៅ អ.វ.ត.ក" ចែងថា៖ "ការដាក់ឯកសារនៅ អ.វ.ត.ក និង ការទាក់ទងទៅវិញទៅមកជាមួយបុគ្គលដែលមានសិទ្ធិដាក់ឯកសារ ត្រូវធ្វើដោយផ្ទាល់ជាមួយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ទៅតាមករណីសមស្រប (ដែលបន្ទាប់ពីនេះហៅកាត់ថា ក្រឡាបញ្ជីដែលពាក់ព័ន្ធ) តាមរយៈមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង"។

២២. មាត្រា ៧.១ នៃឯកសារដែលមានចំណងជើងថា "ការដាក់ឯកសារនៅ អ.វ.ត.ក" ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖ "គ្រប់ឯកសារទាំងអស់ត្រូវដាក់ជាភាសាខ្មែរ រួមជាមួយអង់គ្លេស និង/ឬ បារាំង"។

២៣. មាត្រា ៧.២ នៃឯកសារដែលមានចំណងជើងថា "ការដាក់ឯកសារនៅ អ.វ.ត.ក" ចែងថា៖ "នៅក្នុងកាលៈទេសៈពិសេស សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះណាមួយនៃ អ.វ.ត.ក អាចអនុញ្ញាតឱ្យភាគីណាមួយដាក់ឯកសារជាភាសាបារាំង ឬ ភាសាអង់គ្លេសជាបឋមបាន ប៉ុន្តែបន្ទាប់មកភាគីត្រូវដាក់ឯកសារជាភាសាខ្មែរ ដែលបានបកប្រែរួច ឱ្យបានឆាប់រហ័សបំផុត"។

២៤. មាត្រា ១២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("CPC") ដែលមានចំណងជើងថា "ជំនួយរបស់ក្រឡាបញ្ជី" ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖ "ចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីជានិច្ច។ ក្នុងករណីណាក៏ដោយ ក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ"។

២៥. មាត្រា ១២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលមានចំណងជើងថា "មុខងាររបស់ក្រឡាបញ្ជី" ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖ "សំណុំរឿងស៊ើបសួរត្រូវរក្សាទុកដោយក្រឡាបញ្ជី។ ក្រឡាបញ្ជី

ចម្លងលិខិតនីមួយៗនៃសំណុំរឿងតាមលទ្ធភាពដែលអាចធ្វើបាន។ លិខិតចម្លងនេះត្រូវតែបញ្ជាក់ថាត្រឹមត្រូវតាមលិខិតដើមដោយក្រឡាបញ្ជី។ សេចក្តីចម្លងត្រូវរៀបចំទុកនៅក្នុងសំណុំរឿងបង្ការទុក។ គ្រប់លិខិតនៃសំណុំរឿងត្រូវតែបង់លេខដោយក្រឡាបញ្ជីតាមលំដាប់នៃកាលប្បវត្តិ"។

២៦. មាត្រា ៣៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលមានចំណងជើងថា "ការសរសេរកំណត់ហេតុសវនាការ" ចែងថា៖

> នៅពេលសវនាការ ក្រឡាបញ្ជីសរសេរកំណត់ហេតុសវនាការដែលមានគោលដៅផ្តល់មធ្យោបាយដល់សាលាឧទ្ធរណ៍ ធ្វើការត្រួតពិនិត្យនីត្យានុកូលភាពនៃនីតិវិធី និងបានយល់ដឹងអំពីការពិភាក្សាដេញដោល។
> ក្រឡាបញ្ជីត្រូវខិតខំរៀបរាប់ដោយយកចិត្តទុក អំពីការប្រព្រឹត្តទៅនៃសវនាការ និងកត់ត្រាឱ្យបានត្រឹមត្រូវតាមសំណួរដែលសួរ ព្រមទាំងចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាក្សី និង អ្នកជំនាញ។
> កំណត់ហេតុសវនាការត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងចុះទិដ្ឋាការក្រោយពីការផ្ទៀងផ្ទាត់ដោយប្រធានសវនាការក្នុងរយៈពេល ១០ (ដប់) ថ្ងៃ ក្រោយថ្ងៃប្រកាសសាលក្រម។
> ក្រឡាបញ្ជីណាដែលខ្ជីខ្ជានៅក្នុងការកាន់កាប់កំណត់ហេតុសវនាការ ត្រូវទទួលទណ្ឌកម្មខាងវិន័យ។

## IV. **សំណើ**

### ក. ក្រឡាបញ្ជីរបស់ ក.ស.ច.ស ពុំមានអធ្វានុសិទ្ធិសម្រេចថាតើនៅពេលណាត្រូវបញ្ចូលការដាក់ឯកសាររបស់ភាគីទៅក្នុងសំណុំរឿងទេ

២៧. សន្ទានុក្រមនៃវិធានផ្ទៃក្នុងកំណត់និយមន័យ សំណុំរឿង ថាជា៖

> **សំណុំរឿង** *(Case File = Dossier)* សំដៅទៅដល់សំណុំឯកសារដែលរួមមាន កំណត់ហេតុនៃកិច្ចដែលបានបំពេញនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋម ឬការស៊ើបសួរ ក៏ដូចជាពាក្យសុំរបស់ភាគី សេចក្តីសម្រេចទាំងឡាយដែលបានចេញ និងអ្វីដែលជាឧបសម្ព័ន្ធដែលមាននៅក្នុងគ្រប់ដំណាក់កាលនីតិវិធី រួមទាំងកំណត់ហេតុសវនាការផង។

អនុលោមតាមសន្ទានុក្រមនៃវិធាន សំណុំរឿងចាំបាច់ត្រូវរួមមាន "កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ"មេធាវីការពារក្តីមានការពាក់ព័ន្ធក្នុងនីតិវិធី។ការដាក់ឯកសារនានាពីអ្នកដែលពាក់ព័ន្ធក្នុងរឿងក្តី *ក្នុងចំណោមនោះ* បង្កើតបានជាកំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី។ ការដាក់ឯកសារទាំងនេះត្រូវតែបញ្ចូលក្នុងសំណុំរឿង។

២៨. វិធានមិនបានចែងថា មានតែការដាក់ឯកសារពី "ភាគី" ទេ ដែលត្រូវបញ្ចូលក្នុងសំណុំរឿង។ និយមន័យនៃ "សំណុំរឿង" នៅក្នុងសន្ទានុក្រមនៃវិធានផ្នែកក្នុងចែងថា "ពាក្យសុំរបស់ភាគី" ប៉ុន្តែនិយមន័យនេះក៏បានចែងថា "កំណត់ហេតុសវនាការ"ផងដែរ។ វចនានុក្រម Black's Law Dictionary បានកំណត់និយមន័យនៃពាក្យថា "proceeding" ("កិច្ចដំណើរការនីតិវិធី") ជា "ដំណើរការជាប្រក្រតី និងតាមលំដាប់លំដោយនៃរឿងក្តី រួមទាំង<u>កិច្ចនិងព្រឹត្តិការណ៍ទាំងអស់</u>នៅចន្លោះពេលចាប់ផ្តើម និងពេលចេញសាលក្រម"[33]។ សំណុំរឿង ០០៤ បានចាប់ផ្តើម នៅពេលសហព្រះរាជអាជ្ញាដាក់ដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[34]។ សាលក្រមក្នុងសំណុំរឿង ០០៤ មិនទាន់ចេញនៅឡើយទេ។ "កិច្ចនិងព្រឹត្តិការណ៍ទាំងអស់" នឹងរួមបញ្ចូលទាំងការដាក់ឯកសារពីអ្នកដែលពាក់ព័ន្ធក្នុងសំណុំរឿង ០០៤ ដោយរួមទាំង[redacted]ផង ដែលកើតឡើងនៅ ចន្លោះពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ រហូតដល់ថ្ងៃចេញសាលក្រម។ អនុលោមតាមនិយមន័យនៃ "សំណុំរឿង" នៅក្នុងសន្ទានុក្រមនៃវិធានផ្នែកក្នុង កំណត់ហេតុត្រូវតែធ្វើឡើងចេញពី "កិច្ចនិងព្រឹត្តិការណ៍" ទាំងអស់នេះ ដែលរួមបញ្ចូលទាំងការដាក់ឯកសារពីមេធាវីការពារក្តីផងដែរ។

---

[33] វចនានុក្រម BLACK'S LAW DICTIONARY 1324 (West Publishing Co., បោះពុម្ពលើកទី ៩, ឆ្នាំ ២០០៩) (គូសបញ្ជាក់បន្ថែម)។

[34] មេធាវីការពារក្តីមិនបានទទួលការអនុញ្ញាតក្នុងការពិនិត្យមើលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរអាចរកបាននៅតាមអ៊ីនធឺណេត *អាចរកបាននៅលើគេហទំព័រ* http://img.scoop.co.nz/media/pdfs/1106/CambodiaThird_Introductory_Submission.redacted.pdf។ អត្ថបទដកស្រង់ចេញពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរអាចរកបាននៅក្នុង៖ ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ... ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធសំណើសុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត, ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤, ឯកសារ D121/4/1/4 ("សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះក្នុងការចូលពិនិត្យមើលសំណុំរឿង") ជើងទំព័រ ២ ដែលសរសេរថា៖ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ សេចក្តីជូនដំណឹងនៃការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាស្តីទី ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1"។

២៩. វិធាន ៥៥(៦) ចែងថា ក្នុងដំណាក់កាលស៊ើបអង្កេតនៃកិច្ចដំណើរការនីតិវិធី សំណុំរឿងត្រូវបានរក្សាទុកដោយក្រឡាបញ្ជីរបស់ ក.ស.ច.ស។ ក្រឡាបញ្ជីរបស់ ក.ស.ច.ស ទទួលខុសត្រូវបញ្ចូលការដាក់ឯកសារទៅក្នុងសំណុំរឿង។ សន្ទានុក្រមនៃវិធានចែងថា សំណុំរឿងគ្របដណ្តប់ "គ្រប់ដំណាក់កាលនីតិវិធី"។ ដើម្បីឲ្យគ្រប់ដំណាក់កាលនីតិវិធីត្រូវបានកត់ត្រា សំណុំរឿងត្រូវតែបានធ្វើបច្ចុប្បន្នភាព។ កំណត់ហេតុទាំងមូលនៃកិច្ចដំណើរការនីតិវិធីត្រូវតែបញ្ចូលក្នុងសំណុំរឿងភ្លាមៗ។ វិធាន ៥៥(៦) ចែងថា "សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់ មានសិទ្ធិក្នុងការពិនិត្យ និងថតចម្លងសំណុំរឿង"។ ផ្នែកនេះនៃវិធាន ៥៥(៦) នឹងឥតន័យ ប្រសិនបើសំណុំរឿងមិនត្រូវបានធ្វើបច្ចុប្បន្នភាពនោះទេ។ សំណុំរឿងនឹងត្រូវបានធ្វើបច្ចុប្បន្នភាព និងមានភាពពេញលេញបានលុះត្រាតែសារណាទាំងអស់ត្រូវបានបញ្ចូលភ្លាមៗ។

៣០. វិធាន ៧៦ ពាក់ព័ន្ធជាពិសេសទៅនឹងបណ្តឹងសុំមោឃៈភាពដោយការមិនគោរពវិធានបញ្ញត្តិ។ នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់សំណើសុំប្រកាសមោឃៈភាពដោយសារការមិនគោរពវិធានបញ្ញត្តិ[35]។ វិធាន ៧៦(៣) ចែង*ក្នុងចំណោមចំណុចផ្សេងទៀត*ថា "ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត<u>ត្រូវ</u>ចុះបញ្ជីពាក្យសុំភ្លាម"[36] ដោយមិនផ្តល់ឆន្ទានុសិទ្ធិណាមួយដល់ក្រឡាបញ្ជីរបស់ ក.ស.ច.ស ទេ។ វចនានុក្រម Black's Law Dictionary បានកំណត់និយមន័យនៃពាក្យថា "register" ("ចុះបញ្ជី") ជា "ការធ្វើកំណត់ហេតុ"[37]។ បើតាមការយល់ឃើញរបស់មេធាវីការពារក្តីគឺថា ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនបានបញ្ចូលសំណើសុំប្រកាសមោឃៈភាពទៅក្នុងសំណុំរឿងទេ ទោះជាភ្លាមៗក្តី ឬមិនបានបញ្ចូលទាល់តែសោះតែម្តង។ សំណើសុំប្រកាសមោឃៈភាពមិនទាន់ត្រូវបានចុះបញ្ជីទេ។ ពុំមានកំណត់ហេតុនៃសំណើសុំប្រកាសមោឃៈភាពនៅក្នុងសំណុំរឿងទេ។ ក្រឡាបញ្ជីរបស់ ក.ស.ច.ស បានរំលោភវិធាន ៧៦(៣)។

៣១. វិធាន ៣៩(៦) ចែងថា ឯកសារដែលដាក់នៅ អ.វ.ត.ក ត្រូវដាក់ទៅក្រឡាបញ្ជីដែលពាក់ព័ន្ធ អនុលោមតាមវិធាន និង "សេចក្តីសម្រេចរបស់ចៅក្រម តាមករណីសមស្រប"។ ដូចបានលើកឡើង*ខាងលើ* វិធានបានចែងច្បាស់ថា ការដាក់ឯកសារត្រូវបញ្ចូលក្នុងសំណុំរឿងភ្លាមៗ។ ក្នុងវិធាន ពុំមានបញ្ញត្តិណាមួយផ្តល់ឆន្ទានុសិទ្ធិដល់ក្រឡាបញ្ជីសម្រេច ថាតើ ឬនៅពេលណាដែលត្រូវបញ្ចូល

[35] ពាក្យសុំប្រកាសមោឃភាព។

[36] គូសបញ្ជាក់បន្ថែម។

[37] វចនានុក្រម BLACK'S LAW DICTIONARY 1396 (West Publishing Co., បោះពុម្ពលើកទី ៩, ឆ្នាំ ២០០៩)។

ការដាក់ឯកសារទៅក្នុងសំណុំរឿងនោះទេ។ ពុំមានសេចក្តីសម្រេចណាមួយពីសហចៅក្រមស៊ើបអង្កេតបានសម្រេចអ្វីផ្សេងពីនេះទេ។ ជាងនេះទៀត វិធានក៏មិនអនុញ្ញាតឱ្យចៅក្រមចេញសេចក្តីសម្រេច ឬដីកាបង្គាប់មិនឱ្យបញ្ចូលការដាក់ឯកសារទៅក្នុងសំណុំរឿងដែរ។

៣២. មាត្រា ៣៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖ “ក្រឡាបញ្ជីសរសេរកំណត់ហេតុសវនាការ”។ ទោះបីមាត្រា ៣៤១ អនុវត្តក្នុងពេលជំនុំជម្រះក៏ដោយ តែគោលការណ៍ដូចគ្នានេះក៏ត្រូវអនុវត្តក្នុងការរក្សាកំណត់ហេតុក្នុងដំណាក់កាលស៊ើបអង្កេតដែរ។ បើតាមមាត្រា ១២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាគឺថា “ចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីជានិច្ច”។ ចំណុចនេះក៏ស្រដៀងគ្នាទៅនឹងតួនាទីរបស់ក្រឡាបញ្ជីនៅ អ.វ.ត.ក ដែរ។ ជាក់ស្តែង “កំណត់ហេតុសវនាការ” នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺស្រដៀងគ្នាទៅនឹង “កំណត់ហេតុនីតិវិធី” ក្នុងវិធានដែរ។ ដោយអនុវត្តគោលការណ៍ទាំងនេះក្នុងដំណាក់កាលស៊ើបអង្កេតនៅ អ.វ.ត.ក ក្រឡាបញ្ជីនៅ អ.វ.ត.ក ត្រូវរក្សាសំណុំរឿងដែលបានធ្វើបច្ចុប្បន្នភាពឱ្យបានពេញលេញ។ ការដាក់ឯកសាររបស់មេធាវីការពារក្តី *ក្នុងចំ ណោមការដាក់ឯកសារនានា* ត្រូវតែបញ្ចូលក្នុងសំណុំរឿងភ្លាមៗ។

៣៣. វិធាន ១៦*ស្ទួន* ចែងថា ក្រឡាបញ្ជីនៅ អ.វ.ត.ក “ត្រូវទទួលនីតិសម្បទាពីក្រសួងយុត្តិធម៌”។ ប្រសិនបើក្រឡាបញ្ជីរបស់ ក.ស.ច.ស នៅតែបន្តយកទម្លាប់អនុវត្តបច្ចុប្បន្ន ដោយមិនបញ្ចូល ឬបញ្ចូលដោយយឺតយ៉ាវ នូវការដាក់ឯកសាររបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿងនោះ មេធាវីការពារក្តីនឹងពុំមានជម្រើសអ្វីផ្សេង ក្រៅពីស្នើសុំទៅក្រសួងយុត្តិធម៌ឱ្យចាប់ផ្តើមដំណើរការនីតិវិធីវិន័យមកលើក្រឡាបញ្ជីរបស់ ក.ស.ច.ស នោះទេ[38]។

---

[38] អនុក្រឹត្យលេខ ៤៧ នៃក្រសួងយុត្តិធម៌ដែលមានចំណងជើងថា៖ “អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌” (អនុក្រឹត្យលេខ ៤៧”)។ អនុក្រឹត្យលេខ ៤៧ ត្រូវបានចុះហត្ថលេខាដោយ នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៧។ មាត្រា ២៥ នៃអនុក្រឹត្យលេខ ៤៧ ចែងជាក់លាក់ថា អនុក្រឹត្យនេះនឹងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ (ផ្ទុយពីការឡាយព្រះហស្តលេខា ឬការប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ)។ មាត្រា ៣ នៃអនុក្រឹត្យលេខ ៤៧ ចែងថា “ក្រសួងយុត្តិធម៌ត្រូវទទួលខុស៖ ធានាដំណើរការតុលាការ និងការិយាល័យអយ្យការគ្រប់លំដាប់ថ្នាក់, ពិនិត្យមើលរឿងក្តីនានានៅពេលមានបណ្តឹងពីរូបវន្តបុគ្គល ឬនីតិបុគ្គលអំពីតុលាការ ឬព្រះរាជអាជ្ញា” [បកប្រែ]។ ដោយសារក្រសួងយុត្តិធម៌ទទួលខុសត្រូវតុលាការគ្រប់លំដាប់ថ្នាក់ ចំណុចនេះក៏រួមទាំង អ.វ.ត.ក ដែរ។ ហេតុនេះ មេធាវីការពារក្តីអាចប្តឹងប្រឆាំងនឹងក្រឡាបញ្ជីរបស់ ក.ស.ច.ស បាន អនុលោមតាមមាត្រា ៣ នៃអនុក្រឹត្យលេខ ៤៧។

## ខ. ទង្វើរបស់ក្រុឡាបញ្ជីរបស់ ក.ស.ច.ស ជាទង្វើតាមទំនើងចិត្ត

៣៤. ដូចបានលើកឡើង*ខាងលើ* ទង្វើរបស់ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនអនុលោមតាមវិធានទេ។ ដូចមានការពន្យល់ក្នុងឧបសម្ព័ន្ធ ក្រឡាបញ្ជីរបស់ ក.ស.ច.ស កំពុងបំពេញការងារតាមទំនើងចិត្ត ក្នុងការសម្រេចថាតើ ឬនៅពេលណាដែលគាត់ត្រូវបញ្ចូលការដាក់ឯកសាររបស់មេធាវីការពារក្ដី ទៅក្នុងសំណុំរឿង។ ពុំមានមូលដ្ឋានណាមួយមកសំអាងពីមូលហេតុដែលឱ្យក្រឡាបញ្ជីរបស់ ក.ស.ច.ស ត្រូវដាក់ការដាក់ឯកសាររបស់មេធាវីការពារក្ដីទៅក្នុងសំណុំរឿងយឺតយ៉ាវទេ ប្រសិនបើគាត់បានដាក់បញ្ចូលការដាក់ឯកសារទាំងនោះទៅក្នុងសំណុំរឿងនោះ។ ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនបានផ្ដល់ការពន្យល់គ្រប់គ្រាន់អំពីការបំពេញការងារតាមទំនើងចិត្តនេះទេ។ សារអេឡិកត្រូនិចពីក្រឡាបញ្ជីរបស់ ក.ស.ច.ស ត្រឹមតែនិយាយថា "ខ្ញុំបានទទួលសំណើរបស់លោកហើយ។ ក្រុមមេធាវីរបស់លោកនឹងបានទទួលព័ត៌មានអំពីស្ថានភាពនៃឯកសារនេះក្នុងពេលវេលាសមស្រប"[39] និង "ខ្ញុំបានទទួលសំណើនោះហើយ។ សំណើរបស់លោកនឹងត្រូវបញ្ចូលក្នុងសំណុំរឿងទៅតាមពេលវេលាសមស្រប ហើយក្រុមរបស់លោកនឹងបានទទួលដំណឹងអំពីការបញ្ចូលឯកសារនេះទៅក្នុងសំណុំរឿងមិនខាន"[40] ឬ មិនបានឆ្លើយតបទៅនឹងសារអេឡិកត្រូនិចទាល់តែសោះ។ ការឆ្លើយតបបែបនេះ មិនមែនជាការពន្យល់ពេញលេញអំពីមូលហេតុនោះទេ ហើយជាការបំពេញការងារតាមទំនើងចិត្ត ដែលជាការរំលោភដល់វិធាន។

៣៥. មាត្រា ៧.២ នៃឯកសារដែលមានចំណងជើងថា "ការដាក់ឯកសារនៅ អ.វ.ត.ក" ចែងថា ឯកសារត្រូវដាក់ជាភាសាខ្មែរ និងអង់គ្លេស (ឬបារាំង) លើកលែងតែក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតអនុញ្ញាតឱ្យភាគីដាក់ឯកសារមួយជាភាសាអង់គ្លេស ឬបារាំង ជាបឋម ដោយមានសំណៅបកប្រែជាភាសាខ្មែរនៅពេលក្រោយ។ ក្នុងករណីចំនួនបួន (ក្នុងចំណោមករណីចំនួនប្រាំពីរ) នៅពេលក្រឡាបញ្ជីរបស់ ក.ស.ច.ស បានទទួលសារណាជាពីរភាសារួចហើយ ប៉ុន្តែគាត់បែរជាមិនបានបញ្ចូល ឬបញ្ចូលដោយយឺតយ៉ាវនូវការដាក់ឯកសាររបស់មេធាវីការពារក្ដីទៅក្នុង

---

[39] សារអេឡិកត្រូនិចពីក្រឡាបញ្ជីរបស់ ក.ស.ច.ស ផ្ញើជូនមេធាវីការពារក្ដី ដែលមានចំណងជើងថា "យោង៖ សារណានានានៅក្នុងសំណុំរឿង", ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៤។

[40] សារអេឡិកត្រូនិចពីក្រឡាបញ្ជីរបស់ ក.ស.ច.ស ផ្ញើជូនមេធាវីការពារក្ដី ដែលមានចំណងជើងថា "យោង៖ សារណានានានៅក្នុងសំណុំរឿង", ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤។

សំណុំរឿង[41]។ ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនទំនងជាបានខកខានបញ្ចូល ឬបញ្ចូលដោយយឺតយ៉ាវទៅក្នុងសំណុំរឿងនូវការដាក់ឯកសារនានា ដោយសារការដាក់ឯកសារមិនអនុវត្តតាមសេចក្តីណែនាំអនុវត្តពាក់ព័ន្ធនឹងភាសានោះទេ។ ការពិត ក្នុងករណីមួយ ក្រឡាបញ្ជីរបស់ ក.ស.ច.ស បានបញ្ចូលការដាក់ឯកសាររបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿង នៅពេលដែលឯកសារនោះត្រូវបានដាក់ជាភាសាអង់គ្លេសតែមួយប៉ុណ្ណោះ[42]។

**គ. ក្រឡាបញ្ជីរបស់ ក.ស.ច.ស កំពុងរំលោភបំពានទៅលើសិទ្ធិរបស់[redacted]ក្នុងការការពារក្តីរបស់ខ្លួន**

៣៦. អនុលោមតាមរដ្ឋធម្មនុញ្ញ[43] កិច្ចព្រមព្រៀង[44] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[45] និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[46] [redacted]មានសិទ្ធិការពារក្តីរបស់ខ្លួន។ ដើម្បីការពារក្តីរបស់ខ្លួន [redacted]មានសិទ្ធិទទួលការជំនុំជម្រះ។ ដើម្បីទទួលបានសិទ្ធិជំនុំជម្រះ [redacted] ត្រូវដាក់ឯកសាររបស់ខ្លួនបញ្ចូលក្នុងសំណុំរឿង។ ការមិនបានដាក់ឯកសាររបស់មេធាវីការពារក្តីភ្លាមៗទៅក្នុងសំណុំរឿង ឬមិនបានដាក់ទាល់តែសោះនោះ ( មានមហន្តរាយ<u>ជាក់ស្តែង</u> ប្រសិនបើក្រឡាបញ្ជីរបស់ ក.ស.ច.ស នៅតែបន្តធ្វើទៅតាមទម្លាប់អនុវត្តនាពេលបច្ចុប្បន្ននេះ) ក្រឡាបញ្ជីរបស់ ក.ស.ច.ស កំពុងរំលោភបំពានទៅលើសិទ្ធិរបស់[redacted]ក្នុងការការពារក្តីរបស់ខ្លួន។ តុលាការសិទ្ធិមនុស្សអឺរ៉ុប ដែល អ.វ.ត.ក យកមកធ្វើជាគំរូនោះ បានសម្រេចថា[47]៖

> ពាក់ព័ន្ធនឹងគោលការណ៍ដែលថា អនុសញ្ញាមានគោលបំណងធានា មិនត្រឹមតែសិទ្ធិដែល

---

[41] សំណើសុំចូលពិនិត្យមើលសំណុំរឿង, សេចក្តីផ្តើម។ សារណាស្តីពីការពិចារណាសារជាថ្មីពីការចូលពិនិត្យមើលសំណុំរឿង, សេចក្តីផ្តើម។ ពាក្យសុំប្រកាសមោឃភាព, សេចក្តីផ្តើម។ សំណើសុំការបញ្ជាក់បំភ្លឺ, សេចក្តីផ្តើម។

[42] សារណាស្តីពីការពិចារណាសារជាថ្មីពីការចូលពិនិត្យមើលសំណុំរឿង។

[43] រដ្ឋធម្មនុញ្ញ, មាត្រា ៣១។

[44] កិច្ចព្រមព្រៀង, មាត្រា ១២(២)។

[45] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៥ថ្មី។

[46] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤(៣)(ឃ)។

[47] *រឿងក្តី Ajdaric តទល់នឹង ប្រទេសក្រូអាត*, សំណើលេខ 20883/09, សាលក្រម, ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, កថាខណ្ឌ ៣៣ (ភាសាអង់គ្លេស)។

ជាទ្រឹស្តី ឬការបំភាន់ភ្នែកប៉ុណ្ណោះទេ តែសិទ្ធិដែលយកមកអនុវត្តជាក់ស្តែង និងមានប្រសិទ្ធភាពផង សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនអាចចាត់ទុកថាមានប្រសិទ្ធភាពបានទេ លុះត្រាតែសំណើ និងសេចក្តីសង្កេតនានាពីភាគីត្រូវបានយកមក "ជំនុំជម្រះ" យ៉ាងពិតប្រាកដ ពោលគឺតុលាការបានយកមកពិនិត្យយ៉ាងត្រឹមត្រូវ។

[redacted]មិនអាចត្រូវជំនុំជម្រះជាក់ស្តែង និងមានប្រសិទ្ធភាពនោះទេ ដោយសារការមិនបានបញ្ចូលសារណាការរបស់គាត់ទៅក្នុងសំណុំរឿងជាមុន។ មានតែក្រោយពេលដែលសារណាការរបស់គាត់ត្រូវបានបានបញ្ចូលក្នុងសំណុំរឿងទេ ដែល អ.វ.ត.ក អាចយកសារណាទាំងនោះមកពិនិត្យបាន ហើយ[redacted]ក៏ត្រូវបាន "ជំនុំជម្រះយ៉ាងពិតប្រាកដ"។

៣៧. ដោយមិនបានបញ្ចូលឯកសាររបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿង ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនត្រឹមកំពុងរំលោភបំពានទៅលើសិទ្ធិរបស់[redacted]ក្នុងការការពារក្តីរបស់ខ្លួន ដោយរំលោភសិទ្ធិរបស់[redacted]ទទួលការជំនុំជម្រះប៉ុណ្ណោះទេ តែក៏បានរំលោភដល់សិទ្ធិសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីចូលរួមការជំនុំជម្រះទៅលើបញ្ហានានាដែលពាក់ព័ន្ធដល់ផលប្រយោជន៍របស់ខ្លួនដែរ។ ភាគីផ្សេងៗទៀតក្នុងកិច្ចដំណើរការនីតិវិធីមិនអាចចូលពិនិត្យមើលឯកសាររបស់មេធាវីការពារក្តី ដែលមិនបានបញ្ចូលក្នុងសំណុំរឿងបានទេ។ ភាគីផ្សេងៗក៏មិនអាចធ្វើការឆ្លើយតបបាន។ ប្រសិនបើការដាក់ឯកសាររបស់មេធាវីការពារក្តីប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ សិទ្ធិរបស់ពួកគេដែលទទួលការជំនុំជម្រះក៏កំពុងត្រូវបានរំលោភបំពានដែរ។ នៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "ភាពចាំបាច់ក្នុងការគោរពសិទ្ធិទទួលបានការជំនុំជម្រះនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ... ត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងជាផលប្រយោជន៍យុត្តិធម៌ដ៏មានអត្ថន័យ និងស្របទៅតាមបទដ្ឋានគតិយុត្តិអន្តរជាតិដែលមានលក្ខណៈប្រហាក់ប្រហែល"[48]។ ការពិត សហចៅក្រមស៊ើបអង្កេត

[48] សំណុំរឿង ០០២, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១, ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ E163/5/1/13, កថាខណ្ឌ ៤២។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Jelisić*, សំណុំរឿងលេខ IT-95-10-A, សាលក្រម, ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០០១, កថាខណ្ឌ ៧ (ភាសាអង់គ្លេស) ដែលលើកឡើងក្នុងផ្នែកដែលពាក់ព័ន្ធថា៖ "ការណ៍ដែលថាអង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិសម្រេច*ដោយឯកឯង* ផ្តល់ឲ្យអង្គជំនុំជម្រះនូវសិទ្ធិក្នុងការចេញសេចក្តីសម្រេចថាតើគួរ ឬមិនគួរអញ្ជើញភាគីឲ្យធ្វើបែបនេះ តែការណ៍ដែលថា អង្គជំនុំជម្រះអាចធ្វើបែបនេះបាន មិនបានបន្ធូរបន្ថយនូវកាតព្វកិច្ចធម្មតាជាស្ថាប័នតុលាការដែលត្រូវស្តាប់សក្ខីកម្មភាគីមួយដែលសិទ្ធិរបស់ខ្លួនត្រូវទទួលរងផលប៉ះពាល់ដោយសារសេចក្តីសម្រេចនេះ"។

អន្តរជាតិដឹងពិសិទ្ធិបែបនេះរួចហើយ ដូចមានលើកឡើងនៅក្នុង "ដីកាសម្រេចទាក់ទងនឹងសំណើជាបន្ទាន់របស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ" របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅពេលគាត់ "ជូនដំណឹងដល់ក្រុមមេធាវីការពារក្តីជនសង្ស័យ និងភាគីផ្សេងៗនៅក្នុងសំណុំរឿង ០០៤ ថា គាត់មានបំណងពិចារណាឡើងវិញលើការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ និងការព្យាយាមជូនដំណឹងផ្ទាល់មាត់ ហើយអញ្ជើញក្រុមមេធាវីការពារក្តីជនសង្ស័យនិងភាគីផ្សេងៗ ឱ្យដាក់មតិយោបល់ដែលខ្លួនអាចមានអំពីបញ្ហានេះ"[49]។

**ឃ. ក្រឡាបញ្ជីរបស់ ក.ស.ច.ស កំពុងរំលោភបំពានទៅលើសិទ្ធិរបស់ [redacted] ក្នុងការប្តឹងឧទ្ធរណ៍**

៣៨. ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានសម្រេចថា បណ្តឹងឧទ្ធរណ៍របស់ជនសង្ស័យ (រួមទាំងជនត្រូវចោទផង) តាមវិធាន ៧៤(៣) (ដែលផ្តល់មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបង្គាប់ និងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត) ត្រូវបានអនុញ្ញាត នៅពេលមានបញ្ហាដកហូតពីជនសង្ស័យនូវកិច្ចដំណើរការនីតិវិធីដោយយុត្តិធម៌ និងតទល់គ្នា[50]។ ជាងនេះទៀត អង្គបុរេជំនុំជម្រះ បានទទួលយកបណ្តឹងឧទ្ធរណ៍ដែលលើកឡើងពីបញ្ហាសិទ្ធិជាសារវន្តក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដោយផ្អែកលើវិធាន ២១ តែមួយគត់[51]។ ដើម្បីឱ្យ [redacted] បានអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៤(៣) និងយុត្តិសាស្ត្រនៅ អ.វ.ត.ក នោះ គាត់ត្រូវតែអាចធ្វើកំណត់ហេតុយ៉ាងពិតប្រាកដ ដែលបញ្ចូលនូវកំហុសលើអង្គច្បាប់ អង្គហេតុ ឬការបំពានឆន្ទានុសិទ្ធិក្នុងការពិនិត្យលើបណ្តឹងឧទ្ធរណ៍។ កំណត់ហេតុនោះចាំបាច់ត្រូវបង្ហាញផ្ទុយពីអ្វីដែល [redacted] កំពុងប្តឹងឧទ្ធរណ៍។ [redacted] មិនអាចប្តឹងឧទ្ធរណ៍បានទេ ប្រសិនបើគ្មានកំណត់ហេតុ។ ដោយមិនបានបញ្ចូលការដាក់ឯកសាររបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿងភ្លាមៗ ឬមិនបានបញ្ចូលទាល់តែសោះនោះ ក្រឡាបញ្ជីរបស់

[49] ដីកាសម្រេចទាក់ទងនឹងសំណើជាបន្ទាន់របស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ, ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ D186/1, កថាខណ្ឌ ៧។

[50] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះក្នុងការចូលពិនិត្យមើលសំណុំរឿង, មតិយោបល់របស់ចៅក្រម Chang-Ho Chung និងចៅក្រម Rowan Downing, កថាខណ្ឌ ១ ដល់ ៦។

[51] *សូមមើល ឧទាហរណ៍* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ១៣ ដល់ ១៤។ សាលដីកាលើចម្លើយតបរបស់ អៀង សារី, កថាខណ្ឌ ១៣។

ក.ស.ច.ស កំពុងបដិសេធមិនផ្តល់ឱកាសដល់[redacted]ក្នុងការធ្វើកំណត់ហេតុរបស់ខ្លួន ដែលជាហេតុនាំឱ្យវាក្លាយជាការបដិសេធនូវសិទ្ធិរបស់[redacted]ក្នុងការប្តឹងឧទ្ធរណ៍។

៣៩. មាត្រា ៣៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា "នៅពេលសវនាការ ក្រឡាបញ្ជីសរសេរកំណត់ហេតុសវនាការដែលមានគោលដៅផ្តល់មធ្យោបាយដល់សាលាឧទ្ធរណ៍ ធ្វើការត្រួតពិនិត្យនីត្យានុកូលភាពនៃនីតិវិធី និងបានយល់ដឹងអំពីការពិភាក្សាដេញដោល"។ មាត្រា ៣៤១ កំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានូវសំអាងហេតុ ដែលតម្រូវឱ្យមានកំណត់ហេតុដែលបានធ្វើបច្ចុប្បន្នភាពពេញលេញ ពោលគឺក្នុងគោលបំណងដើម្បីផ្តល់ឱ្យសាលាឧទ្ធរណ៍នូវមធ្យោបាយក្នុងការពិនិត្យទៅលើនីត្យានុកូលភាពនៃកិច្ចដំណើរការនីតិវិធី និងយល់ដឹងពីការពិភាក្សាដេញដោល។

**ង. ទង្វើរបស់ក្រឡាបញ្ជីរបស់ ក.ស.ច.ស រំលោភបំពានលើគោលការណ៍សច្ចភាពគតិយុត្តិ**

៤០. វិធាន ២១ ចែងថាសច្ចភាពគតិយុត្តិត្រូវតែយកមកអនុវត្តនៅ អ.វ.ត.ក ដើម្បីការពារសិទ្ធិជាសារវ័ន្តរបស់ជនសង្ស័យ[52]។ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ សច្ចភាពគតិយុត្តិត្រូវបានកំណត់និយមន័យក្នុងន័យនៃភាពដែលអាចព្យាករណ៍បានជាអតិបរមាពីឥរិយាបថរបស់មន្ត្រី[53]។ ឥរិយាបថរបស់ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនអាចព្យាករណ៍បានទេ។ គេមិនអាចព្យាករណ៍គាត់បានទេថា តើពេលណាគាត់នឹងបញ្ចូលការដាក់ឯកសាររបស់[redacted]ទៅក្នុងសំណុំរឿងនោះ។ ក្រឡាបញ្ជីរបស់ ក.ស.ច.ស កំពុងត្រួតត្រាការចូលពិនិត្យមើលព័ត៌មានពីមេធាវីការពារក្តីទៅក្នុងសំណុំរឿង ដែលជាការរំលោភទៅលើវិធាន។ និយាយរួម ក្រឡាបញ្ជីរបស់ ក.ស.ច.ស កំពុងកាន់កាប់អំណាចដែលគាត់ពុំមាន ទៅតាមឆន្ទៈផ្ទាល់របស់ខ្លួន។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា សច្ចភាពគតិយុត្តិគឺជា "ទិដ្ឋភាពជាសារវ័ន្តមួយក្នុងចំណោមទិដ្ឋភាពជាសារវ័ន្តនានានៃ

[52] "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពី <u>សច្ចភាពផ្លូវច្បាប់</u> និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង" (គូសបញ្ជាក់បន្ថែម)។

[53] "នៅក្នុងប្រព័ន្ធអឺរ៉ុបដីគោក សច្ចភាពគតិយុត្តិត្រូវបានកំណត់និយមន័យក្នុងន័យនៃភាពដែលអាចព្យាករណ៍បានជាអតិបរមាពីឥរិយាបថរបស់មន្ត្រី"។ ERIK CLAES ET AL., **ការប្រឈមមុខនឹងការកំហិតនៃច្បាប់** (FACING THE LIMITS OF THE LAW) 92 (Springer Publishing Co. ឆ្នាំ ២០០៩)។

នីតិរដ្ឋ"[54]។ ហេតុនេះ ដោយមិនបញ្ចូល ឬបញ្ចូលដោយយឺតយ៉ាវនូវសារណារបស់មេធាវីការពារក្ដីទៅក្នុងសំណុំរឿងក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនត្រឹមតែប្រព្រឹត្តផ្ទុយនឹងវិធាន ២១ ប៉ុណ្ណោះទេ តែគាត់ក៏បានរំលោភទៅលើទិដ្ឋភាពជាសារវ័ន្តមួយនៃនីតិរដ្ឋផងដែរ។

## ច. ទង្វើរបស់ក្រឡាបញ្ជីរបស់ ក.ស.ច.ស ពុំមែនជាទង្វើដែលអនុវត្តនៅ "តុលាការគំរូ" ទេ

៤១. បើតាមអង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក គឺជាតុលាការគំរូសម្រាប់ប្រទេសកម្ពុជា[55]។ គេហទំព័ររបស់ អ.វ.ត.ក ក៏ធ្លាប់បានលើកឡើងនូវគោលនយោបាយដែលថា អ.វ.ត.ក ត្រូវដើរតួនាទីជាតុលាការគំរូសម្រាប់ប្រទេសកម្ពុជាដែរ[56]។ ទោះជាយ៉ាងណាក្ដី សម្រាប់ហេតុផលនានាដែលមេធាវីការពារក្ដីមិនបានដឹង គោលនយោបាយនេះត្រូវបានដកចេញពីគេហទំព័ររបស់ អ.វ.ត.ក វិញហើយ។ នៅក្នុងតុលាការគំរូ ក្រឡាបញ្ជីរបស់ ក.ស.ច.ស ដែលអនុវត្តតាមវិធាន នឹងបញ្ចូលឯកសារទៅក្នុងសំណុំរឿងភ្លាមៗ។ ទោះជាយ៉ាងណាក្ដី នៅ អ.វ.ត.ក នាពេលបច្ចុប្បន្ន ក្រឡាបញ្ជីរបស់ ក.ស.ច.ស កំពុងប្រើប្រាស់តួនាទីរដ្ឋបាលដើម្បីបដិសេធសិទ្ធិរបស់ [redacted] ក្នុង

---

[54] *រឿងក្ដី Şahin តទល់នឹង ប្រទេសទួរគី,* ពាក្យសុំលេខ 13279/05 Eur. Ct. H.R, Gr. Ch., (ឆ្នាំ ២០១១), កថាខណ្ឌ ៥៦ (ភាសាអង់គ្លេស)។

[55] អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា បើទោះបីជា អ.វ.ត.ក មិនមានអាណត្តិការងារដោះស្រាយនូវភាពខ្វះចន្លោះដោយផ្ទាល់នៅក្នុងយន្តការនៃតុលាការជាតិដែលបានបង្កើតឡើងដើម្បីធានាទ្រង់ទ្រាយនូវឯករាជភាពរបស់ស្ថាប័នតុលាការក៏ដោយ "តែវាអាចជា*តុលាការគំរូ* សម្រាប់ជួយជំរុញឱ្យមានការធានានូវឯករាជភាព និងសុចរិតភាពនៅក្នុងស្ថាប័នតុលាការ")។ សេចក្ដីសម្រេចលើបណ្ដឹងរបស់លោក អៀង សារី ដែលប្ដឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន, កថាខណ្ឌ ១៤ (គូសបញ្ជាក់បន្ថែម)។

[56] អ.វ.ត.ក ត្រូវបានបង្កើតឡើងដោយមានជំនួយពីអន្តរជាតិ ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីតុលាការនឹងស្របតាមបទដ្ឋាននៃយុត្តិធម៌អន្តរជាតិ។ បើតាមគេហទំព័រពីមុនរបស់ អ.វ.ត.ក គឺថា៖ "រដ្ឋាភិបាលកម្ពុជាបានទទូចថា *ដើម្បីជាផលប្រយោជន៍របស់ប្រជាជនកម្ពុជា* តុលាការត្រូវតែបង្កើតឡើងនៅប្រទេសកម្ពុជា ដោយប្រើប្រាស់បុគ្គលិក និងចៅក្រមកម្ពុជា រួមជាមួយបុគ្គលិកបរទេស។ *ប្រទេសកម្ពុជាបានអញ្ជើញឱ្យមានការចូលរួមពីអន្តរជាតិ ដោយសារប្រព័ន្ធតុលាការកម្ពុជានៅមានភាពទន់ខ្សោយ និងលក្ខណៈអន្តរជាតិនៃបទល្មើសទាំងនោះ និង ដើម្បីជួយឱ្យស្របទៅតាមបទដ្ឋាននៃយុត្តិធម៌អន្តរជាតិ*។ កិច្ចព្រមព្រៀងរវាង អ.ស.ប ត្រូវបានសម្រេចនៅខែ មិថុនា ឆ្នាំ ២០០៣ ដោយពន្យល់លម្អិតពីរបៀបដែលសហគមន៍អន្តរជាតិនឹងជួយ និងចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ។ តុលាការពិសេសថ្មីនេះត្រូវបានបង្កើតឡើងដោយសាររដ្ឋាភិបាល និង អ.ស.ប តែងតាំងពីស្ថាប័នទាំងពីរ។ វាជាតុលាការកម្ពុជាដោយមានការចូលរួមពីអន្តរជាតិដែលនឹងអនុវត្តតាមបទដ្ឋានអន្តរជាតិ។ *តុលាការនេះនឹងផ្ដល់នូវគំរូថ្មីមួយសម្រាប់ដំណើរការតុលាការនៅប្រទេសកម្ពុជា*"។ ចំណុចនេះអាចរកបាននៅឯគេហទំព័រ៖ http://www.eccc.gov.kh/english/about_eccc.aspx (គូសបញ្ជាក់បន្ថែម)។ នាពេលនេះ ផ្នែកនេះនៅត្រឹមតែថា៖ "គេហទំព័រដែលបានស្នើសុំមិនអាចរកបានទេ"។

ការទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមទំនើងចិត្ត។ ក្រឡាបញ្ជីរបស់ ក.ស.ច.ស កំពុងជ្រៀតជ្រែកទៅក្នុងដំណើរការរបស់តុលាការ។ ទង្វើរបស់ក្រឡាបញ្ជីរបស់ ក.ស.ច.ស ពុំមែនជាទង្វើនៅក្នុងតុលាការគំរូមួយសម្រាប់កម្ពុជាទេ។ ការពិត ទង្វើរបស់ក្រឡាបញ្ជីរបស់ ក.ស.ច.ស កំពុងធ្វើឲ្យអាប់ឱនដល់កេរដំណែលរបស់ អ.វ.ត.ក ទៅវិញទេ។

**អាស្រ័យហេតុនេះ** សម្រាប់សំអាងហេតុនានាដូចបានរៀបរាប់ខាងលើ មេធាវីការពារក្តីសូមស្នើសុំដោយគោរពទៅសហចៅក្រមស៊ើបអង្កេតមេត្តាចេញដីកាបង្គាប់ឲ្យក្រឡាបញ្ជីរបស់ ក.ស.ច.ស បញ្ចូលការដាក់ឯកសាររបស់[redacted]ទៅក្នុងសំណុំរឿងភ្នាម។

សូមលោកចៅក្រមមេត្តាទទួលយកសារណានេះដោយគោរព។

**សូ មូស្សេរ្នី** | **Suzana TOMANOVIĆ**

**សហមេធាវីការពារក្តីរបស់**[redacted]

ចុះហត្ថលេខានៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៤